**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ១៣៤ អនក្រ.បក

**អនុក្រឹត្យ**
**ស្តីពី**
**ការដាក់ឱ្យប្រើនីតិវិធីគ្រប់គ្រងប្រតិបត្តិការរួម**
**សម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលត្រូវបានប្រកាសឱ្យប្រើដោយច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលត្រូវបានប្រកាសឱ្យប្រើដោយច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២១/០១៨ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលត្រូវបានប្រកាសឱ្យប្រើដោយច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រា១ .-**

ដាក់ឱ្យប្រើនីតិវិធីគ្រប់គ្រងប្រតិបត្តិការរួមសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន (ភ.រ.ឯ.) ដូចមានខ្លឹមសារភ្ជាប់មកជាមួយអនុក្រឹត្យនេះ។

**មាត្រា២ .-**

នីតិវិធីគ្រប់គ្រងប្រតិបត្តិការរួមសម្រាប់គម្រោង ភ.រ.ជ. ដែលត្រូវបានដាក់ឱ្យប្រើ ក្រោមអនុក្រឹត្យនេះ រួមមាន:

១- នីតិវិធីគ្រប់គ្រងប្រតិបត្តិការគម្រោង ភ.រ.ជ. ភាគ១ ស្ដីពីគោលនយោបាយ និងនីតិវិធី

២- នីតិវិធីគ្រប់គ្រងប្រតិបត្តិការគម្រោង ភ.រ.ជ. ភាគ២ ស្ដីពីគោលការណ៍ណែនាំ រួមមាន:

- គោលការណ៍ណែនាំស្ដីពីការធ្វើអត្តសញ្ញាណកម្ម និងការជ្រើសរើសគម្រោង ភ.រ.ជ.
- គោលការណ៍ណែនាំស្ដីពីមូលនិធិអភិវឌ្ឍន៍គម្រោង ភ.រ.ជ.
- គោលការណ៍ណែនាំស្ដីពីការគាំទ្រពីរដ្ឋសម្រាប់គម្រោង ភ.រ.ជ.
- គោលការណ៍ណែនាំស្ដីពីការគ្រប់គ្រងកិច្ចសន្យា ភ.រ.ជ.

៣- នីតិវិធីគ្រប់គ្រងប្រតិបត្តិការគម្រោង ភ.រ.ជ. ភាគ៣ ស្ដីពីនីតិវិធីគ្រប់គ្រងលទ្ធកម្មគម្រោង។

**មាត្រា៣ .-**

នីតិវិធី និងគោលការណ៍ណែនាំផ្សេងទៀតពាក់ព័ន្ធនឹងគម្រោង ភ.រ.ជ. ត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីនៃគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ៥ កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្ដេច ឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ